ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៩៩.កយ.ព្រទ-២០០៥

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>ជម្រាបមក</u>**

លោកប្រធានតុលាការខេត្ត-ក្រុង

លោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង

**<u>កម្មវត្ថុ:</u>** អំពីសំណើសុំផ្តល់ព័ត៌មានបន្ថែមក្នុងករណីព្រហ្មទណ្ឌ ដែលមានជនជាប់ចោទជាជនបរទេស ។

**<u>យោង:</u>** លិខិតលេខ ៦៩៩២ កបទ-សរអ ឡក ២ ចុះថ្ងៃទី២៤-១១-២០០៤ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

ខ្ញុំសូមជម្រាបលោកប្រធាន និងលោកព្រះរាជអាជ្ញាថា ក្រសួងយុត្តិធម៌បានទទួលលិខិតដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ស្នើឱ្យក្រសួងយុត្តិធម៌ផ្តល់ព័ត៌មានបន្ថែមអំពីករណីព្រហ្មទណ្ឌ ដែលមានជនជាប់ចោទជាជនបរទេសទៅតុលាការខេត្ត-ក្រុង ទាំងអស់អំពីឈ្មោះជាអក្សរឡាតាំងនឹងជាពិសេសលេខលិខិតឆ្លងដែនរបស់ជនល្មើសបើមានច្បាប់ថតចម្លងលិខិតឆ្លងដែនកាន់តែប្រសើរ ដើម្បីអោយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិមានមូលដ្ឋានគ្រប់គ្រាន់ជូនដំណឹងដល់ស្ថានទូតបរទេសនៃជនជាប់ចោទ ។

សេចក្តីនេះ សូមអស់លោកចាត់ការផ្តល់ឯកសារ និងព័ត៌មានផ្សេងៗដូចបានរៀបរាប់ខាងលើផ្ញើមកក្រសួងយុត្តិធម៌តាមករណីនីមួយៗ ដើម្បីក្រសួងចាត់ការតាមច្បាប់តទៅ ។

ភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥

**រដ្ឋមន្ត្រី**

**អង្គ វង្សវឌ្ឍានា**

<u>ចម្លងជូន</u>

-ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
ដើម្បីជ្រាបជាព័ត៌មាន

-ឯកសារ-កាលប្បវត្តិ